**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៥ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម ដែលសរសេរជាអក្សរកាត់ថា **គ.ប.ផ.ក.** ដើម្បីទប់ស្កាត់រាល់សកម្មភាពពាក់ព័ន្ធនឹងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម។

**ប្រការ២ .-**

**គ.ប.ផ.ក.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | ប្រធាន |
| - អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធានប្រចាំការ |
| - អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធាន |
| - អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | អនុប្រធាន |
| - អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប | អនុប្រធាន |



https://www.moj.gov.kh/kh/law-regular

- អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប សមាជិក
- មេញ្ញាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ១រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប សមាជិក
- តំណាងវិទ្យាស្ថានស្តង់ដារកម្ពុជានៃក្រសួងឧស្សាហកម្ម
  វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ប.ផ.ក**. ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ៣.-**

**គ.ប.ផ.ក**. មានភារកិច្ចដូចខាងក្រោម៖

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីទប់ស្កាត់រាល់សកម្មភាពពាក់ព័ន្ធនឹងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម
- រៀបចំផែនការសកម្មភាពបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពដល់មន្ត្រីមានសមត្ថកិច្ចក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម
- រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងជំរុញការងារផ្សព្វផ្សាយអប់រំដល់សាធារណជនអំពីផលប៉ះពាល់នៃការប្រើប្រាស់ផលិតផលក្លែងក្លាយ ដើម្បីឱ្យមានការយល់ដឹងជាទូទៅអំពីបញ្ហាប្រឈមនិងផលប៉ះពាល់ ក្នុងគោលបំណងឈានដល់ការលុបបំបាត់នូវការផលិត ការកែច្នៃ ការនាំចេញ ការនាំចូល ការលក់ដូរ និងការប្រើប្រាស់ផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម
- ផ្តួចផ្តើមគំនិតក្នុងការកំណត់វិធានការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម
- ជំរុញឱ្យមានការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម ឱ្យមានប្រសិទ្ធភាពខ្ពស់
- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ អង្គការ និងដៃគូអភិវឌ្ឍនានា ដើម្បីគាំទ្រសកម្មភាពប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម
- រាយការណ៍អំពីការអនុវត្តការងារក្នុងដំណាក់កាលបំពេញភារកិច្ចជាក់ស្តែងនីមួយៗជូនប្រមុខរាជរដ្ឋាភិបាលនិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។



https://www.moj.gov.kh/kh/law-regular

**ប្រការ៤ .-**

**គ.ប.ផ.ក**. មានសិទ្ធិប្រើត្រាបស់ក្រសួងមហាផ្ទៃ ដើម្បីបំពេញការងាររបស់ខ្លួន។

**ប្រការ៥ .-**

**គ.ប.ផ.ក**. មានថវិកាសម្រាប់ដំណើរការរដ្ឋបាល។ ថវិកានេះត្រូវស្ថិតនៅក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ។

**ប្រការ៦ .-**

**គ.ប.ផ.ក**. មានលេខាធិការដ្ឋានមួយដែលមានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ផ្នែករដ្ឋបាល
- ផ្នែកបច្ចេកទេស។

សមាសភាពនិងរបៀបរបបធ្វើការងារនៃលេខាធិការដ្ឋានខាងលើ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ៧ .-**

សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១៥០ សសរ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម, សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ២៩ សសរ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពបន្ថែមនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម, ប្រកាសរបស់ក្រសួងមហាផ្ទៃលេខ៥៦១៩ ប្រ.ក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម, ប្រកាសរបស់ក្រសួងមហាផ្ទៃលេខ៣៣០៩ ប្រ.ក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការសម្រួលសមាសភាពក្រុមការងារជំនាញអន្តរក្រសួងដើម្បីជួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១២ រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular